## អាជ្ញាយុកាលនៃការចោទប្រកាន់ (statute of limitation)

អាជ្ញាយុកាល ជាវេលា ដែលក្រោយពីការបញ្ចប់ពេលវេលានោះ ការចោទប្រកាន់នឹងមិនអាចត្រូវបានធ្វើបានឡើយ។ មាត្រា២៩ នៃលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ចែងច្បាស់ថា បទឧក្រិដ្ឋក្រោមសមត្ថកិច្ចខ្លួន មិនមានអាជ្ញាយុកាលឡើយ។

នៅមានបញ្ហាចម្រូងចម្រាស់ជាច្រើន ថាតើបទល្មើសឧក្រិដ្ឋប្រភេទណា មានអាជ្ញាយុកាល។ បទឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានអះអាងថា មានអាជ្ញាយុកាល។ សម្រាប់បទល្មើសទារុណកម្ម ICTY បានអះអាងថា អាជ្ញាយុកាលមិនអនុវត្តចំពោះបទល្មើសប្រភេទនេះទេ ដោយសារ ការហាមឃាត់ទារុណកម្មជាវិធានអន្តរជាតិខ្ពស់បំផុត (*jus cogens*)។

ប្រទេសមួយចំនួន ដូចជា ប្រទេសចិន សហរដ្ឋអាមេរិក ហ្គ្រិក បានកំណត់រយៈពេលសម្រាប់ចោទប្រកាន់បទប្រល័យពូជសាសន៍ បទប្រឆាំងនឹងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 522-524)។

**ខ្លឹមសារបន្ថែម៖** ក្រមព្រហ្មទណ្ឌកម្ពុជា ចែងមិនអនុវត្តអាជ្ញាយុកាលចំពោះ បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប្រល័យពូជសាសន៍ និងបទឧក្រិដ្ឋកម្មសង្គ្រាម។ ដើម្បីកាត់បន្ថយភាពចម្រូងចម្រាស់ សន្ធិសញ្ញា ស្តីពី ការមិនអនុវត្តអាជ្ញាយុកាលចំពោះបទឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិត្រូវបានអនុម័ត ឡើង (convention on non-statute of limitation to international crime)។